# មេរៀនទី ១២៩៖ ស្ទេផានឈរមាំដើម្បីព្រះ

កិច្ចការ ៦៖៨-៧៖៦០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/AKPmo2hmO3g

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/FW6WFipflis

**គោលបំណង៖** យើងបានថ្វាយកិត្តិនាមដល់ទ្រង់នៅពេលដែលយើងឈរមាំជាមួយនឹងទ្រង់

**ខគម្ពីរចងចាំ៖ កិច្ចការ ៧៖៥៥** *"តែដែលគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ នោះក៏សំឡឹងមើលទៅលើមេឃ ឃើញសិរីល្អនៃព្រះ និងព្រះយេស៊ូវឈរនៅខាងព្រះហស្តស្តាំ។"*

**ចំរៀង** ( *យូធូបលីង* )៖

១.គឺជាការល្អដែលសរសើរព្រះ https://youtu.be/Z91SULEHfho

២.ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo

៣.ចូរមានកម្លាំងនិងមានចិត្តក្លាហានចុះ https://youtu.be/Mr7oyUvG7U8

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត "អៀវគ្នាទាត់បាល់"



សម្ភារៈដែលត្រូវការ៖ បាល់ ២

១. ចែកកុមារជា ២ក្រុម ហើយឲ្យពួកគេចាប់ដៃគូពីរៗនាក់

២. ក្រុមនីមួយៗត្រូវយកបាល់ម្នាក់មួយ ហើយឲ្យពួកគេអៀវគ្នា

៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ គូរទីមួយត្រូវទាត់បាល់ (ដោយអៀវដៃគូរបស់ខ្លួន) ទៅឲ្យដល់ចុងម្ខាងនៃថ្នាក់រៀន ហើយរត់ត្រឡប់មកកាន់ទីចាប់ផ្តើមវិញ។

៤. នៅពេលដែលគូរទី១ ត្រឡប់មកដល់ទីវិញ គូរទីពីរត្រូវបន្តទាត់បាល់ និងអៀវគ្នាផង

៥. ក្រុមណាដែលអាចលេងបានគ្រប់គ្នាមុន នឹងឈ្នះល្បែងនេះ

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាដៃគូរបស់ពួកគេមានកា រធ្ងន់ក្នុងការអៀវដៃគូរបស់ខ្លួនក៏ដោយ តែពួកគេនៅតែបន្តអៀវដៃគូររហូតដល់ចប់ល្បែងនេះ។ ក៏ដូចគ្នានេះ ដែរពួកយើងត្រូវតែឈរមាំសម្រាប់ព្រះយេស៊ូវរហូតដល់ថ្ងៃស្លាប់។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់មានការភ័យខ្លាច នៅពេលដែលនិយាយប្រាប់អ្នកណាម្នាក់ពីព្រះយេស៊ូវប៉ុន្តែអ្នកនៅតែធ្វើវាឬទេ? តើមានអ្នកខឹងនឹងអ្នកនៅពេលដែលអ្នកជឿព្រះ ឬធ្វើអ្វីដែលជារឿងត្រឹមត្រូវដែរឬទេ?តើអ្នកមានអារម្មណ៍ភ័យខ្លាចក្នុងការនិយាយពីសេចក្តីពិតអំពីព្រះទៅកាន់នរណាម្នាក់ដែរឬទេ? ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលមិនខ្លាចក្នុងការនិយាយពីព្រះយេស៊ូវ បើទោះបីជាគាត់ត្រូវបានគេគម្រាមសម្លាប់ក៏ដោយ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះយេស៊ូវបានសុគត និង រស់ឡើងវិញមក អ្នកដែលដើរតាមទ្រង់បាននៅតែបន្តនិយាយពីទ្រង់ពីអ្វីដែលមាននៅក្នុងចិត្តរបស់គេនៅគ្រប់កន្លែងដែលគេបានទៅ។ នៅក្នុងចំណោមអ្នកដែលជឿនោះ មាន

បុរសម្នាក់ឈ្មោះស្ទេផាន។ គាត់ជាមនុស្សដែលមានសេចក្តីជំនឿ និងពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ គាត់បានធ្វើនូវរឿងអស្ចារ្យជាច្រើនឱ្យហ្វូងមនុស្សបានឃើញ។

មនុស្សជាច្រើនមិនជឿថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះនោះទេ។ គេក៏មិនចូលចិត្តនូវអ្វីដែលស្ទេផានបាននិយាយផងដែរ។ ពួកគេបាននិយាយកុហកពីលោកស្ទេផាន ហើយធ្វើឲ្យមនុស្សជាច្រើនស្អប់គាត់។ គេបានចាប់ស្ទេផានទៅកាត់ទោស។ ទោះបីជានៅពេលវេលាចុងក្រោយនៃជីវិតរបស់គាត់ក៏ដោយ ក៏ស្ទេផាននៅតែព្យាយាមធ្វើយ៉ាងណាឱ្យមនុស្សជឿលើព្រះយេស៊ូវដែរ។ រឿងនេះធ្វើឱ្យមនុស្សកាន់តែខឹង នឹងស្ទេផាន ដោយពួកគេបានទាញគាត់ចេញទៅខាងក្រៅទីក្រុង រួចចោលគាត់នឹងដុំថ្មសម្លាប់។ ក្នុងពេលដែលហ្វូងមនុស្សកំពុងតែចោលគាត់នឹងថ្មនោះ ស្ទេផានបានអធិស្ឋានថា "ឱព្រះអម្ចាស់យេស៊ូវអើយ សូម ទទួលវិញ្ញាណទូលបង្គំផង" គាត់បានលុតជង្គង់ចុះរួចនិយាយថា "ឱព្រះអម្ចាស់អើយ សូមកុំរាប់បាប នេះ ដល់គេឡើយ" រួចគាត់ក៏ស្លាប់ទៅ។

ស្ទេផានគឺជាមនុស្សទីមួយដែលជាគឺជាមនុស្សម្នាក់ដែលស៊ូស្លាប់ដោយសារតែសេចក្តីជំនឿរបស់គាត់។ ស្ទេផានត្រូវបានគេចោលនឹងដុំថ្មពីព្រោះតែគាត់បានចែកចាយពីព្រះយេស៊ូវ។ នៅពេលដែលគាត់ឈរនៅខាងព្រះ គឺមានន័យថាស្ទេផានបានថ្វាយនូវកិត្តិនាមដល់ទ្រង់។ មនុស្សជាច្រើន បានជឿដល់ព្រះយេស៊ូវដោយព្រោះតែទង្វើរបស់ស្ទេផាន។

ព្រះវិញ្ញាណបរិសុទ្ធនិងព្រះយេស៊ូវបានគង់នៅជាមួយនឹងស្ទេផាន នៅពេលដែលគាត់បានឈរមាំជាមួយព្រះ បើទោះបីជាលទ្ធផលចុងក្រោយគាត់ត្រូវស្លាប់ក៏ដោយ។ មានមនុស្សជាច្រើននៅមិនទាន់ ប្រឈមមុខនឹង សេចក្តីស្លាប់នៅពេលដែលយើងនិយាយពីព្រះយេស៊ូវនៅឡើយទេ ប៉ុន្តែព្រះបានសន្យាថាទ្រង់គង់ជាមួយ យើងមិនថាយើងស្ថិតនៅក្នុងស្ថានភាពបែបណានោះទេ។ មិនថានៅពេលយើងនិយាយប្រាប់មនុស្សថា ព្រះយេស៊ូវស្រឡាញ់ពួកគេ ឬក៏ប្រាប់មិត្តភក្តិយើងថាកុំឱ្យលួចរបស់អ្វីមួយក៏ដោយ ប៉ុន្តែសូមចាំថាការឈរ មាំជាមួយព្រះគឺយើងបានថ្វាយកិត្តិនាមទៅដល់ទ្រង់។

ជាថ្មីម្តងទៀត ការឈរមាំជាមួយព្រះគឺមានន័យថា គឺយើងធ្វើតែរឿងអ្វីដែលត្រឹមត្រូវទោះបីជាអ្នកដទៃ មិនឯកភាពជាមួយយើងក៏ដោយ។ គឺមានន័យថានិយាយសេចក្តីពិតពីព្រះនៅពេលដែល អ្នកដទៃនិយាយមិនពិតពីទ្រង់។ ហើយគឺមានន័យថាប្រាប់អ្នកដទៃពីព្រះយេស៊ូវបើទោះ បីជាគេគិតថាវាជារឿងមិនពិតក៏ដោយ។

ព្រះយេស៊ូវគឺជាគម្រូដ៏ល្អឥតខ្ចោះម្នាក់ដែលបានឈរមាំជាមួយនឹងព្រះជាម្ចាស់។ ព្រះយេស៊ូវទ្រង់មានបន្ទូលអំពីសេចក្តីពិតពីព្រះបើទោះបីជាមានមនុស្សជាច្រើនបានស្អប់ទ្រង់ក៏ដោយ។ ទ្រង់បានស្តាប់បង្គាប់ព្រះនៅគ្រប់កាលៈទេសៈទាំងអស់ ទោះបីជាព្រះអង្គត្រូវសុគតនៅលើឈើឆ្កាងក៏ដោយ។

ដោយព្រោះតែមានទ្រង់ជាគម្រូរបស់យើង យើងក៏អាចឈរមាំដើម្បីព្រះជាម្ចាស់ដូចគ្នា។ យើងអាចធ្វើដូចជា ស្ទេផាននិងប្រាប់មនុស្សគ្រប់គ្នា "ព្រះយេស៊ូវស្រឡាញ់អ្នក!" យើងក៏អាចធ្វើដូចជាស្ទេផាន និងរៀន អំពី រឿងរ៉ាវនៅក្នុងព្រះគម្ពីរ។ យើងអាចធ្វើដូចជាស្ទេផាន ដោយការស្រឡាញ់ព្រះជាម្ចាស់ឱ្យអស់ពីចិត្ត ដោយ ការស្រឡាញ់មនុស្សដែលនៅជុំវិញខ្លួនយើង បើទោះបីជាអ្នកនោះធ្វើមិនល្អដាក់យើងក៏ដោយ។ នៅគ្រប់ ពេលដែលយើងធ្វើដូចនេះ គឺយើងបានឈរមាំដើម្បីព្រះជាម្ចាស់របស់យើង និងថ្វាយកិត្តិនាម ដល់ទ្រង់ ផងដែរ។

## ៦. សំនួរពិភាក្សា

១. តើស្ទេផានក្រោកឈរដើម្បីព្រះដោយរបៀបណា? *(គាត់ស្រឡាញ់ព្រះ ស្រឡាញ់មនុស្ស ធ្វើការអស្ចារ្យ ប្រាប់មនុស្សពីព្រះយេស៊ូវ និងបានអត់ទោសដល់អ្នកដែលបានសម្លាប់គាត់ទៀតផង)*

២. តើមានរឿងអ្វីកើតឡើងចំពោះគាត់?

*(មនុស្សមិនជឿថាព្រះយេស៊ូវគឺជាព្រះ ហើយបានចោលគាត់នឹងដុំថ្ម)*

៣. តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យមនុស្សមិននៅឈរមាំជាមួយនឹងព្រះ? *(សូមឱ្យកុមារឆ្លើយ)*

៤. តើអ្នកធ្វើយ៉ាងដូចម្តេចដើម្បីឈរមាំជាមួយនឹងព្រះ? *(សូមឱ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត "ឈរមាំដើម្បីព្រះ"



សម្ភារៈដែលត្រូវការ៖ កែវក្រដាស និងតុ

១. ចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជាជួរ តាមក្រុម

២. ឲ្យកែវក្រដាសទៅកុមារម្នាក់១ នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទី១មកពីក្រុមទាំងពីរត្រូវរត់យកកែវទៅដាក់នៅលើតុ

៣. កុមារបន្ទាប់ត្រូវរត់ទៅកាន់តុហើយដាក់កែវរបស់គេពីលើកែវរបស់សមាជិកក្រុមខ្លួន

៤. លេងល្បែងនេះរហូតដល់ក្រុមណាមួយអាចដាក់កែវក្រដាសនោះលើគ្នាបាន៦កែវ។

៥. ប្រសិនបើកែវទាំងនោះដួលពួកគេត្រូវចាប់ផ្តើមសារជាថ្មី

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពេលខ្លះយើងគឺមានការពិបាកក្នុងការឈរមាំសម្រាប់ព្រះយេស៊ូវ វាក៏ពិបាកដូចជាការដែលធ្វើឲ្យកែវឈរមាំអីចឹងដែរ។ ប៉ុន្តែយើងត្រូវតែឈរមាំសម្រាប់ព្រះយេស៊ូវជានិច្ច ពីព្រោះទ្រង់ជាស្តេចដ៏មានព្រះចេស្តារបស់យើង!

## ៨. ខគម្ពីរចងចាំ

**កិច្ចការ ៧៖៥៥** *"តែដែលគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ នោះក៏សំឡឹងមើលទៅលើមេឃ ឃើញសិរីល្អនៃព្រះ និងព្រះយេស៊ូវឈរនៅខាងព្រះហស្តស្តាំ។"*

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌រូបភាព "ស្ទេផានបានឈរមាំជាមួយនឹងព្រះ"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ទំនាក់ទំនងកាន់តែរីកចម្រើនជាមួយព្រះយេស៊ូវ បង្កើតនូវសេចក្តីជំនឿ និងភាពក្លាហាននៅ ក្នុងចិត្ត និងជីវិតរបស់គ្រីស្ទបរិស័ទ។ ភាពក្លាហាននេះអនុញ្ញាតឱ្យយើងនិយាយការពិត នៅពេលប្រឈមមុខនឹងគ្រោះថ្នាក់។ ការនិយាយការពិតពីព្រះយេស៊ូវ នឹងមិនបានធ្វើឱ្យអ្នក ស្លាប់នោះឡើយ ប៉ុន្តែមានគ្រីស្ទបរិស័ទជាច្រើនបានស្លាប់ ហើយក៏មានអ្នកជឿជាច្រើនទៀតបានរងទុក្ខ រហូតដល់ស្លាប់ ដោយព្រោះតែពួកគេបានព្យាយាមនិយាយពីសេចក្តីជំនឿ និងសេចក្តីពិត។ សូមចំណាយពេលអរព្រះគុណព្រះ ចំពោះបុរស និងស្ត្រីណាដែលមានរឿងដូចជាស្ទេផាន ដែលពួកគេបានលះបង់ជីវិតរបស់ពួកគេសម្រាប់ប្រយោជន៍នៃដំណឹងល្អ។ តើអ្នកអាចថ្លែងអំណរគុណចំពោះពួកគេបានដោយរបៀបណានៅក្នុងជីវិតរបស់អ្នក? អ្នកបានចូលរួមធ្វើកិច្ចការជាមួយនឹងពួកគេទាំងនោះ នៅរាល់ពេលដែលអ្នកនិយាយពីសេចក្តីពិតអំពីជីវិត និងការងាររបស់ព្រះយេស៊ូវគ្រីស្ទ។

# ស្ទេផានបានឈរមាំជាមួយនឹងព្រះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________